**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ៖ ១៨០០ អ.ក

ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

សំណុំរឿងជំនុំជម្រះលេខ៖ ២៥៣ ជរ

ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១

សាលក្រមលេខ៖ ៧៦ (ប)

ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាល

**នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ដោយមានសមាសភាព៖**

*ចៅក្រមជំនុំជម្រះ*

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

*តំណាងអយ្យការ*

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

*ក្រឡាបញ្ជីសវនាការ*

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

**លើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៨០០ អ.ក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដែលមាន៖**

១-ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ាង** ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកឡានដឹកកម្មកររោងចក្រ រៀនថ្នាក់ទី១២ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកណ្ដាល នៅលីវ ឪពុកឈ្មោះ [redacted] ទ្រី (រស់) ម្ដាយឈ្មោះ [redacted] សៀកលីម (រស់) ទោសពីមុនគ្មាន។ **(ក្រៅឃុំ)**

២-ជនជាប់ចោទឈ្មោះ [redacted] **គឹមសៀប** ភេទស្រី អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរស្ពៃជ្រក់ រៀនថ្នាក់ទី៨ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្នភូមិដំរីឆ្លង ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល ប្ដីឈ្មោះ [redacted] លាង មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ឡេង (រស់) ម្ដាយឈ្មោះ [redacted] ហំងហេង (រស់) ទោសពីមុនគ្មាន។ **(ក្រៅឃុំ)**

-ជាប់ចោទពីបទ: **គំរាមកំហែងនិងញុះញង់ឱ្យមានការរើសអើង** ប្រព្រឹត្តនៅភូមិព្រៃករុន ឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ តាមមាត្រា ២៣១ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted] **ម៉េង ហ៊ាង**។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **គឹមសៀប**។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងហ៊ត ភេទប្រុស កើតឆ្នាំ១៩៩៦ ទីលំនៅភូមិព្រៃករុន ឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្ដាល។



Scanned with CamScanner

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេង ហ៊ត។

-បានឃើញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់លេខ ១៣១ ដក.ជរផ/២១ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**អង្គហេតុនៃរឿងមានដូចតទៅ៖**

កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ម៉ោង ៤:៥១នាទីរសៀល ឈ្មោះ [redacted] សេងហ៊ត និងមន្ត្រីមានសមត្ថកិច្ច រួមទាំងប្រជាពលរដ្ឋជាច្រើន បានចូលរួមត្រួតពិនិត្យ និងចុះវាស់វែងផ្លូវទំហំទទឹង ៦ម៉ែត្រ និងបណ្តោយ ២៩០ម៉ែត្រ ស្ថិតនៅភូមិព្រែករុន ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល។ ពេលនោះប្រជាពលរដ្ឋពីរគ្រួសារបានសង់របងធ្វើពីថ្មរំលោភលើផ្លូវ សាធារណៈ ក៏មានការចុះត្រួតពិនិត្យ និងវាស់វែង ស្រាប់តែមានឈ្មោះ [redacted] គីមសៀប បានស្រែកខ្លាំងៗថា ជាមនុស្សមានចំណេះដឹងដែរ តែអន់ជាងសត្វតិរច្ឆាន និងជាមេចោរលួចកាត់ដើមឈើ ក៏មានឈ្មោះ [redacted] ម៉េងហ៊ង បានប្រើពាក្យសំដីបន្តទៀតថា ជាពួកអាក្រៅស្រុក និងបានគំរាមថា វាមិនឱ្យយើងបានសុខ យើងក៏មិនឱ្យវាបានសុខដែរ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** បានឆ្លើយពេលសវនាការ ថាៈ នៅថ្ងៃកើតហេតុទី២៦ ខ្លួនបានជិះម៉ូតូឆ្លងកាត់ម៉ាក់យាយរបស់ខ្លួន គាត់ឆ្លើយថា គេមកកាប់ដើមឈើ ខណៈនោះមានជនជាប់ចោទមិនស្គាល់ឈ្មោះប្រហែល ០៧នាក់មកកាប់ដើមឈើ ដើមស្វាយ១ដើម ដើមត្របែក១ដើមធំ ដើមហ្លុងខ្វងប្រហែល១០ដើម ខណៈនោះ វាឲ្យអ្នកណាគេមករញ៉េរញ៉ៃកាប់ដើមឈើនៅខាងក្រោយផ្ទះរបស់ខ្លួន។ ឈ្មោះ [redacted] សេងហ៊ត ខ្លួនមិនស្គាល់ទេ ខ្លួនមិនបានជេរគេថាជាសត្វតិរច្ឆាន ជាចោរលួចកាប់ដើមឈើទេ។ សំលេងដែលគេលួចថត គឺមិនមែនជាសំលេងខ្លួនទេ។

-ជនជាប់ចោទឈ្មោះ [redacted] **គីមសៀប** បានឆ្លើយពេលសវនាការ ថាៈ ខ្លួនត្រូវជាម្តាយមីងរបស់ឈ្មោះ [redacted] ម៉េងហ៊ង នៅថ្ងៃកើតហេតុម៉ោង ៣រសៀល ខ្លួនបានមកផ្ទះម្តាយខ្លួន ដែលនៅក្នុងភូមិហៅខ្លួនមកដោះស្រាយរឿងកាប់ដើមឈើ ដើម្បីបើកផ្លូវ។ អ្នកកាប់ដើមឈើ ខ្លួនមិនស្គាល់ទេ ដើមឈើធំៗ ដើមអំពិលបារាំង ដើមស្វាយទំហំ ២ អោប ដែលខ្លួនមិនចង់ឈ្លោះគ្នា ចាំដោះស្រាយតាមសន្តិវិធី។ ខ្លួនមិនបានគំរាមកំហែង ឬ ជេរទេ។ ខ្លួនបាននិយាយទៅអ្នកកាប់ដើមឈើដែលមិនស្គាល់អន់ជាងសត្វតិរិច្ឆានទៅទៀត។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] សេងហ៊តទេ ម្តាយខ្លួនមិនបានសង់របងលយលើផ្លូវទេ។ គេកាប់ដើមឈើរបស់ម្តាយខ្លួននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ ដើមឈើ របងម្តាយខ្លួនធ្វើយូរហើយ។ ខ្លួនមិនដឹងថា គេលួចថតសំលេងខ្លួនថា ម៉ិចនោះទេ គឺកន្លែងគេកាប់ដើមឈើឃ្លាតពីម៉ុងជីដូនជីតាចំនួនពីរ ហើយដើមឈើនោះជាដើមហុងស៊ុយត្រជាក់ត្រជុំគ្រួសារខ្លួន។

-ក្រឡាបញ្ជីអានអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងហ៊ត** នៅដំណាក់កាលអយ្យការថាៈ ខ្លួនតំណាងអោយ ១០ គ្រួសារ សូមរក្សាតាមពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ទុកដដែរ និងសូមបន្ថែមខ្លឹមសារថា ស្នើសុំគោលការណ៍ឲ្យខាងសាលាស្រុកចុះវាស់វែងផ្លូវមួយកន្លែងស្ថិតនៅចំណុចភូមិព្រែករុន ឃុំព្រែកគយ

ស្រុកស្អាង ខេត្តកណ្តាល។ ខ្លួនសំណូមពរសុំឱ្យជនជាប់ចោទសងការខូចខាតនិងសេវាមេធាវីចំនួន៤០លានរៀលព្រមទាំងជម្ងឺចិត្តចំនួន ២០ លានរៀល សរុបចំនួន ៦០ លានរៀល។

-សាក្សីបំភ្លឺឈ្មោះ [redacted] **ភា** ភេទស្រី អាយុ ៣៤ឆ្នាំ បានឆ្លើយពេលសវនាការថា ខ្លួនជាអ្នកជិតខាងរបស់គូភាគី នៅថ្ងៃកើតហេតុអាជ្ញាធរចុះវាស់វែង ហើយដីខាងក្រោយជាដីឯកជនគេចង់ពង្រីកផ្លូវចាក់បេតុង តែខ្លួនមិនលឺគេជជែក ឬ គំរាមកំហែងទេ តែបានលឺគេជជែកគ្នាខ្លាំងៗ។ ឈ្មោះ [redacted]សេងហ៊ត ខ្លួនស្គាល់ជាអ្នកផ្ទះជាប់គ្នា ។

-សាក្សីបំភ្លឺឈ្មោះ [redacted] **សេងគីម** ភេទប្រុស អាយុ ៤១ឆ្នាំ ខ្លួនជាជំទប់ឃុំទី២ឃុំព្រែកគយធ្វើបីឆ្នាំហើយក៏ជាអ្នកដោះស្រាយរឿងវិវាទនេះនៅសាលាឃុំ។ សំណូមពរពីឯកជនដែលនៅដីខាងក្រោយសុំពង្រីកផ្លូវ ដើម្បីចាក់បេតុង ពេលវាស់ផ្លូវគឺចំដើមឈើ ក៏ឈ្មោះ [redacted] សេងហ៊ត ជាមេការឱ្យឧកញ៉ាដែលមានដីនៅខាងក្រោយឡូឡាខ្លាំង។ ខ្លួនវាស់ផ្លូវដើម្បីរាយការណ៍ជូនអភិបាលស្រុក។ មុនពង្រីកផ្លូវមានទទឹងប្រហែលនឹងជាង ៣ម៉ែត្រ។ ក្រោយពង្រីកមានទទឹងប្រហែល ៥,៧ម៉ែត្រ។ អ្នកកាប់ដើមឈើឈ្មោះ [redacted] សេងហ៊ត ជាអ្នកហៅឯកជនមកកាប់។ ខ្លួនមិនបានលឺថាឈ្មោះ [redacted] ម៉េងហ៊ង និងឈ្មោះឡេង គីមសៀប ជេរគំរាមកំហែងទេ តែលឺឡូឡា ខ្លួនក៏បានជួយសំរបសំរួលដោយប្រាប់ដើម បណ្តឹងរដ្ឋប្បវេណីថា ជនជាប់ចោទរងអយុត្តិធម៌ហើយចាំបាច់ចង់ទាមទារសំណងចោទប្រកាន់គាត់ទៀត។ ឈ្មោះ [redacted]សេងហ៊ត ខ្លួនស្គាល់ តែគ្មានតួនាទីអ្វីទេ។ ជនជាប់ចោទទាំងពីរនាក់ជាមនុស្សល្អ ឬកោងកាចដល់ក្នុងមូលដ្ឋាននោះទេ ខ្លួនមិនដឹងដើមបណ្តឹងរដ្ឋប្បវេណីល្អ ឬទេ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ ក្រោយពីសួរដេញដោលជនជាប់ចោទទាំងពីរនាក់មកឃើញថា ជនជាប់ចោទបានបដិសេធន៏ថា ពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ និងសាក្សីក៏មិនដឹងដែរ។ ដូច្នេះតំណាងអយ្យការស្នើសុំតុលាការពិនិត្យស្តាប់ខ្សែថតសំលេង និងសុំតំកល់បទចោទប្រកាន់ដដែល។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **គីមសៀប** ថាៈ តាមអង្គហេតុ គឺបានកាប់ដើមឈើរួចហើយ គឺនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០។ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ទៅជួបមេឃុំដើម្បីដោះស្រាយ។ គាត់ថាឱ្យដើមបណ្តឹងរដ្ឋប្បវេណីនូវពាក្យមួយចំនួន។ ពាក់ព័ន្ធឃុបឃិតរៀបរៀងឱ្យមានការរើសអើង។ ភស្តុតាងជាអាត់សំលេងមានការកាត់តសំលេង សុំបដិសេធន៏នូវភស្តុតាង។ គោលបំណងប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបំណងទារសំណងចំនួន ១០០០ដុល្លា ដើម្បីបញ្ចប់រឿង។ តាមមាត្រា ១៣ នៃក្រមនីតិវិធី និងព្យសនកម្ម ដែលកូនក្តីធ្វើឱ្យខូចខាត ដូច្នេះសុំបដិសេធន៏ចោលការទាមទារនោះពុំមានការខូចខាតអ្វីទេ។ មាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ សុំបដិសេធ ចោល។ ឈ្មោះ [redacted] សេងហ៊ត ជាជំនួយការមេធាវីចង់សាកចំណេះដឹងរបស់គាត់ដើម្បីបានសំណង។ សំណូមពរឱ្យឈ្មោះ [redacted] គីមសៀប ដើម្បីបានរួចពីការចោទប្រកាន់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** ថា ចំពោះអង្គហេតុ ខ្លួនបដិសេធពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សេងហ៊ត នូវពាក្យបណ្តឹងនេះគឺជាការមិនពិត។ មុនអង្គហេតុនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០២០ គឺនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ មានការកាប់ដើមឈើរបស់ជនជាប់ចោទ ដែលទទួលរងនូវភាពអយុត្តិធម៌ ហើយដើមបណ្តឹងរដ្ឋប្បវេណីមកប្តឹងជនជាប់ចោទថែមទៀត។ អង្គច្បាប់មាត្រា ២៣១ និងមាត្រា ៤៩៦ ពីបទគំរាមកំហែង និងមានការញុះញង់ឱ្យមានការរើសអើង។ សាក្សីជាជំទប់ឃុំទី២ អត់បានលឺជនជាប់ចោទគំរាមកំហែងញុះញង់



Scanned with CamScanner

ផង។ ការលួចថតសំលេងសុំច្រានចោល វិមតិសង្ស័យត្រូវបានជាប្រយោជន៏មកជនជាប់ចោទតាមមាត្រា ៣៥១ នៃក្រម នីតិវិធីព្រហ្មទណ្ឌ។ ស្នើសុំតុលាការពិនិត្យពិចារណា និងលើកលែងចោទប្រកាន់។

+ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** សុំលើកលែងចោទនិងបញ្ចប់រឿងក្តីនេះ។

+ជនជាប់ចោទឈ្មោះ [redacted] **គឹមសៀប** សុំបញ្ចប់រឿង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីបំភ្លឺ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ និងភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌ ពីអយ្យការអមសាលាដំបូងខេត្តកណ្តាល ដែលមានជន ជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** ភេទប្រុស អាយុ ២៣ឆ្នាំ និងឈ្មោះ [redacted] **គឹមសៀប** ភេទប្រុស អាយុ ៤៣ឆ្នាំ ពីបទៈ **គំរាមកំហែង និងញុះញ៉ង់ឲ្យមានការរើសអើង** តាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់លេខ ១៣១ ដក.ជរផ/២១ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទ យោងតាមមាត្រា ២៨៩ ,មាត្រា ២៩១ និងមាត្រា ៣៤៨ នៃ **ក្រមនីតិវិធីព្រហ្មទណ្ឌ**។

២-ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច , ចម្លើយរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាល ព្រមទាំងភស្តុតាង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** និងជនជាប់ចោទឈ្មោះ [redacted] **គឹមសៀប** ពិតជាបានប្រើពាក្យទៅលើដើមបណ្តឹងរដ្ឋប្បវេណីដោយថា ជាមនុស្សមានចំណេះដឹងដែរ តែអន់ជាងសត្វតិរច្ឆានទៅទៀត និងគំរាមថា មិនឲ្យបានសុខ ខណៈពេលដើមបណ្តឹងរដ្ឋប្បវេណី និងសមត្ថកិច្ចចុះទៅវាស់វែងផ្លូវ និងកាប់ដើមឈើតាមដងផ្លូវទទឹង ៦ម៉ែត្រ និងបណ្តោយ ២៩០ម៉ែត្រ នៅភូមិព្រែករុន ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** និងឈ្មោះ [redacted] **គឹមសៀប** គឺជាអង្គហេតុគ្រប់នឹងធាតុផ្សំបទល្មើស **អំពើគំរាមកំហែង និងញ៉ុះញ៉ង់ឲ្យមានការរើសអើង** ដែលមានចែងតាមមាត្រា ២៣១ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ។

៣-ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** និងឈ្មោះ [redacted] **គឹមសៀប** មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៤-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** និងឈ្មោះ [redacted] **គឹមសៀប** ពីបទៈ **គំរាមកំហែង និងញ៉ុះញ៉ង់ឲ្យមានការរើសអើង** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។



Scanned with CamScanner

៥-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទៈ ស្នើសុំឲ្យលើកលែងបទចោទប្រកាន់នោះ គឺមិនត្រឹមត្រូវទេ។

៦-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** ភេទប្រុស អាយុ ២៣ឆ្នាំ និងឈ្មោះ [redacted] **គឹមសៀប** ភេទប្រុស អាយុ ៤៣ឆ្នាំ ពីបទៈ **គំរាមកំហែង និងញុះញង់ឲ្យមានការរើសអើង** ប្រព្រឹត្តនៅភូមិព្រៃករុន ឃុំព្រៃគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ដែលត្រូវផ្ដន្ទាទោសតាមមាត្រា ២៣១ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ។

៧-អំពើដែលជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** និងឈ្មោះ [redacted] **គឹមសៀប** បានប្រព្រឹត្តបានធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។ ក៏ប៉ុន្តែជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយជាបទមជ្ឈិម ,ជនជាប់ចោទនៅក្រៅឃុំ ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទ តុលាការនឹងពិចារណា។

៨-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងហ៊ត** បានប្ដឹងសុំទាមទារសំណង និងជម្ងឺចិត្តចំនួនសរុប ៦០.០០០.០០០ (ហុកសិបលាន)រៀល ពីជនជាប់ចោទ មានលក្ខណៈច្រើនពេក ដូច្នេះចំណុចនេះតុលាការនឹងពិនិត្យពិចារណាតាមភាពសមរម្យ និងជាក់ស្ដែង។

## <u>ហេតុដូច្នេះសម្រេច</u>

១/-ផ្ដន្ទាទោសឈ្មោះ [redacted] **ម៉េងហ៊ង** ភេទប្រុស អាយុ ២៣ឆ្នាំ និង ឈ្មោះ [redacted] **គឹមសៀប** ភេទស្រី អាយុ ៤៣ ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេលចំនួន ១(មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរ ពីបទៈ **គំរាមកំហែង និងញុះញង់ឲ្យមានការរើសអើង** ប្រព្រឹត្តនៅភូមិព្រៃករុន ឃុំព្រៃគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ តាមមាត្រា ២៣១ មាត្រា ៤៩៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

២/-បង្គាប់ឲ្យឈ្មោះ [redacted] **ម៉េងហ៊ង** និងឈ្មោះ [redacted] **គឹមសៀប** រួមគ្នាផ្ដល់សំណងជម្ងឺចិត្តទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងហ៊ត** ចំនួន ១.០០០.០០០(មួយលាន)រៀល ការទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ម៉េងហ៊ង** ,ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **គឹមសៀប** ,ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ,កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ រក្សាសិទ្ធិប្ដឹងទាស់ ឬប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** — ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ** — ហត្ថលេខា និងត្រា [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ១៤ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ខេត្តកណ្ដាល ,ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner